# ព័ត៌មានស្តីពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ លើកទី៤(ដូសជំរុញ) សម្រាប់ជនបរទេសដែលរស់នៅក្នុងប្រទេសកូរ៉េ(អាយុលើសពី៦០ឆ្នាំ)

ចំនួនអត្រាការរីករាលដាលមេរោគបំប្លែងអូមីក្រុង នៅក្នុងស្ថានភាពអ្នកជំងឺនិងចំនួននាក់ស្លាប់ នៃមនុស្សចាស់កំពុងកើនឡើង, ហើយដើម្បីការការពារជំងឺឆ្លងដ៏ធ្ងន់ធ្ងរ ចាប់ពីអ្នកស្លាប់ដោយសារតែការឆ្លងមេរោគកូវីដ១៩ យើងខ្ញុំសូមជម្រាបជូនដំណឹងថា ការអនុវត្តការចាក់វ៉ាក់សាំងកូវីដ១៩ លើកទី៤ដល់ជនបរទេសដែលរស់នៅក្នុងប្រទេសកូរ៉េ អាយុលើសពី៦០ឆ្នាំ ដែលមានដូចខាងក្រោមនេះ

■ គោលដៅចាក់វ៉ាក់សាំង

○អាយុលើសពី៦០ឆ្នាំ(ថ្ងៃខែឆ្នាំកំណើត មុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៦២) ក្នុងចំណោមមនុស្សចាស់ **ដែលរស់នៅក្នុងប្រទេសកូរ៉េ ឬក្រៅប្រទេស ដែលបានបញ្ចប់ការចាក់វ៉ាក់សាំងលើកទី៣រួច លើសពី៤ខែ(១២០ថ្ងៃ)ទៅ** គឺត្រូវទទួលការចាក់វ៉ាក់សាំង, ហើយក្នុងចំណោមមនុស្សចាស់ដែលមានអាយុលើសពី៨០ឆ្នាំ ដែលមានការប្រឈមនិងហានិភយ័ខ្ពស់ **យើងសូមណែនាំអោយទទួលការចាក់វ៉ាក់សាំលើកទី៤។**

*ទោះបីអ្នកមានប្រវត្តិឆ្លងជំងឺកូវីដ១៩ មុននិងក្រោយចាក់វ៉ាក់សាំងលើកទី៣ក៏ដោយ ប្រសិនបើសាមីខ្លួនត្រូវការនោះអាចទទួលការចាក់វ៉ាក់សាំងបាន។

■ ប្រភេទវ៉ាក់សាំង និងរយៈពេលចាក់

○ការទទួលចាក់វ៉ាក់សាំង mRNA(ហ្វាយសឺរ,ម៉ូតូណា)និង វ៉ាក់សាំង ណូវ៉ាវ៉ាក។

○អ្នកដែលមានអាយុលើស៦០ឆ្នាំ ក្នុងចំណោមមនុស្សចាស់ដែលបានចាក់វ៉ាក់សាំងលើកទី៣រួចលើសពី៤ខែ(១២០ថ្ងៃ)ទៅ គឺអាចទទួលចាក់វ៉ាក់សាំងលើកទី៤បាន។ ប៉ុន្តែកន្លែងដែលប្រឈម និងការឆ្លងមេរោគជាក្រុម ដូចជាមន្ទីរពេទ្យថែទាំចាស់ជរា, មជ្ឍមណ្ឌល(រួមទាំងទីកន្លែងលើកកម្ពស់សុខភាពផ្លូវចិត្ត) ចំពោះអ្នកដែលមានប្រព័ន្ធភាព ស៊ាំចុះខ្សោយគឺចាំបាច់កាត់បន្ថយចន្លោះពេលក្នុងការចាក់វ៉ាក់សាំងបានចាប់ពី៣ខែ(៩០ថ្ងៃ)បន្ទាប់ពីការការចាក់វ៉ាក់សាំងលើកទី៣។

■ កាលវិភាគ នឹងទីតាំង

○**ការកក់ទុកជាមុនចាប់ពី** (ច័ន្ទ)**ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២** តទៅបាន, ការទទួលកក់ចាក់វ៉ាក់សាំង ចាប់ពី(ច័ន្ទ)**ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២** តទៅបាន។

○**ការចាក់ដោយមិនបាច់កក់ទុក**ករណីមានវ៉ាក់សាំងនៅសេសសល់ នៅស្ថាប័ន្ទវេជ្ជសាស្ត្រដែលផ្តល់ជូននោះ អ្នកអាចចាក់វ៉ាក់សាំង ចាប់ពី(**ព្រហស្បតិ៍**)**ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២** តទៅបាន។

○**ទីកន្លែងចាក់វ៉ាក់សាំងគឺ** អាចទទួលបាននៅស្ថាបន័វេជ្ជសាស្ត្រដែល**អនុវត្តការចាក់ថ្នាំបង្ការកូវីដ១៩** មិនថាអ្នកមានធានារ៉ាប់រងសុខភាពឬអត់នោះទេ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមិនអាចទៅទទួលថ្នាំបង្ការ នៅស្ថាបន័វេជ្ជសាស្ត្រទេនោះ អ្នកអាចចាក់វ៉ាក់សាំងនៅមណ្ឌលសុខភាពសាធារណៈបាន អាស្រយ័លើលក្ខខណ្ឌរបស់រដ្ឋាភិបាលក្នុងតំបន់។

■ វិធីនៃការកក់

**១. ជនបរទេសដែលមានអាយុលើសពី៦០ឆ្នាំដែលបានបញ្ចប់ការចាក់ថ្នាំបង្ការបឋមនិងលើកទី៣ នៅក្នុងប្រទេសកូរ៉េ**

**១)ជនដែលបានចុះឈ្មោះជាជនបរទេស៖** អាចធ្វើការកក់តាមរយៈអនឡាយឬទូរស័ព្ទ ដូចគ្នានិងការចាក់វ៉ាក់សាំងជាមូលដ្ឋានដែរ។

①ការកក់តាមរយៈអនឡាយ៖ សាមីខ្លួននិងអ្នកកក់ជំនួស អាចចូលទៅប្រព័ន្ធកក់ទុកមុននៃការចាក់ថ្នាំបង្ការកូវីដ-១៩ (https://ncvr.kdca.go.kr)

② ការកក់ទុកតាមទូរស័ព្ទ៖ ការកក់តាមរយៈមជ្ឍមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺកូរ៉េ (☏១៣៣៩) ឬរដ្ឋាភិបាលក្នុងតំបន់។

③ការចាក់ដោយមិនកក់ទុក៖ ចាក់ភ្លាមៗនៅថ្ងៃដែលចង់ចាក់ បន្ទាប់ពីការចុះឈ្មោះជាបឋមក្នុងបញ្ជី នៃស្ថាបន័វេជ្ជសាស្ត្រ (ទូរស័ព្ទបញ្ជាក់តាមរយៈខ្សែទូរស័ព្ទ)

* អាចកក់វ៉ាក់សាំងដែលនៅសេសសល់តាមរយៈSNS

**២)ជនដែលមិនបានចុះឈ្មោះជាជនបរទេស**(រួមទាំងជនបរទេសខុសច្បាប់)៖ អ្នកចាក់វ៉ាក់សាំងបឋម ឬចាក់វ៉ាក់សាំងលើកទី៣ បន្ទាប់ពីទទួលបានលេខគ្រប់គ្រងបណ្តោះអាសន្នពីមណ្ឌលសុខភាពសាធារណៈ អ្នកអាចកក់តាមទូរស័ព្ទឬទៅកក់ផ្ទាល់នៅស្ថាបន័ សម្រាប់ចាក់វ៉ាក់សាំង(ស្ថាបន័វេជ្ជសាស្ត្រឬមណ្ឌលសុខភាពសាធារណៈ)

*នៅពេលចេញលេខគ្រប់គ្រងបណ្តោះអាសន្ន មិនត្រូវបានទាមទារអោយបង្ហាញអត្តសញ្ញាណ ដូចជាលិខិតឆ្លងដែន,ប័ណ្ណចុះឈ្មោះជនបរទេសទេ។

**២.ជនបរទេសដែលមានអាយុលើសពី៦០ឆ្នាំ ដែលបានបញ្ចប់ការចាក់វ៉ាក់សាំងជាបឋមនិងចាក់វ៉ាក់សាំងលើកទី៣នៅបរទេស (រួមបញ្ចូលទាំងជនបរទេសដែលស្នាក់នៅរយៈពេលខ្លីតិចជាង៩០ថ្ងៃ)**

○ត្រូវយកអត្តសញ្ញាណប័ណ្ណរបស់អ្នកទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត, ឬបន្ទាប់ពីទទួលបានលេខគ្រប់គ្រងបណ្តោះអាសន្ន និងចុះឈ្មោះប្រវត្តិចាក់ថ្នាំនៅក្រៅប្រទេសរួច, អ្នកអាចធ្វើការកក់ទុកតាមទូរស័ព្ទ ឬទៅកាន់ស្ថាប័នចាក់វ៉ាក់សាំង(ស្ថាបន័វេជ្ជសាស្ត្រ ឬមណ្ឌលសុខភាពសាធារណៈ)ដោយផ្ទាល់។

※ សេចក្តីយោង

-**ព័ត៌មានដែលពាក់ព័ន្ធនិងអត្តសញ្ញាណ គឺត្រូវបានប្រើសម្រាប់គោលបំណងចាក់វ៉ាក់សាំងតែប៉ុណ្ណោះ និងយោងតាមប្រព័ន្ធលើកលែងកិច្ចជូនដំណឹង គឺមិនត្រូវបានជូនដំណឹងការពិតការស្នាក់នៅដោយខុសច្បាប់ផ្សេងៗ ទៅកាន់ការិយាល័យអន្តោប្រវេសន៍ទេ។**

-សម្រាប់ព័ត៌មានបន្ថែម សូមមើលនៅលើគេហទំព័រ របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺកូរ៉េ(KCDC) សម្រាប់ការចាក់ថ្នាំបង្ការកូវីដ-១៩ 누리집(https://ncv.kdca.go.kr)